ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ឆ្នាំទី ១២ លេខ ៨០ សប្តាហ៍ទី ៤ ថ្ងៃទី ៣១ ខែតុលា ឆ្នាំ ២០១២

រាជកិច្ច

ផ្សាយដោយ

ទីស្តីការគណៈរដ្ឋមន្ត្រី

តម្លៃជាវ

១ ច្បាប់	៥.០០០ រៀល
១ ខែ	៤០.០០០ រៀល
៣ ខែ	១២០.០០០ រៀល
៦ ខែ	២៤០.០០០ រៀល
១២ ខែ	៤៨០.០០០ រៀល

(ត្រូវបង់តម្លៃជាវជាមុន)

សារបាន

ព្រះរាជក្រម ព្រះរាជក្រឹត្យ អនុក្រឹត្យ សេចក្តីសម្រេច សារាចរ ប្រកាស

មាតិកា

I. ព្រះរាជខុទ្ទកាល័យព្រះមហាក្សត្រ

ព្រះរាជក្រឹត្យ

១២-១០-២០១២-ព្រះរាជក្រឹត្យ នស/រកត/១០១២/៩៣២ ស្តីពី ការតម្លើងឋានន្តរស័ក្តិ ជូន មន្ត្រីរាជការ ចំនួន ០២ រូប ពីឋានន្តរស័ក្តិវរមន្ត្រី ទៅឋានន្តរស័ក្តិឧត្តមមន្ត្រី នៃ ក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល របស់ក្រសួងព័ត៌មាន ៨០១៥

១២-១០-២០១២-ព្រះរាជក្រឹត្យ នស/រកត/១០១២/៩៣៤ ស្តីពី ការតម្លើងឋានន្តរស័ក្តិ ថ្នាក់ ឧត្តមសេនីយ៍ទោ ជូនលោកឧត្តមសេនីយ៍ត្រី **លឹម ឡូខ** នៃក្របខ័ណ្ឌនគរបាលជាតិ កម្ពុជា ក្រសួងមហាផ្ទៃ ៨០១៦

១៣-១០-២០១២-ព្រះរាជក្រឹត្យ នស/រកត/១០១២/៩៣៦ ស្តីពី ការតម្លើងថ្នាក់ ប្រចាំឆ្នាំ ជូន មន្ត្រីរាជការ ចំនួន ០៦ រូប ក្នុងឋានន្តរស័ក្តិឧត្តមមន្ត្រី នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រង រដ្ឋបាល របស់ក្រសួង ស្ថាប័ន ៨០១៧

១៣-១០-២០១២-ព្រះរាជក្រឹត្យ នស/រកត/១០១២/៩៣៧ ស្តីពី ការបញ្ចប់មុខតំណែងឯកឧត្តម **ម៉ៅ រិទ្ធីថា** ពីអនុរដ្ឋលេខាធិការក្រសួងធម្មការ និង សាសនា ៨០១៩

១៣-១០-២០១២-ព្រះរាជក្រឹត្យ នស/រកត/១០១២/៩៣៨ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿង ឥស្សរិយយស តាមលំដាប់ថ្នាក់ ចំពោះ ព្រះសង្ឃ សប្បុរសជន និង មន្ត្រីរាជការ ចំនួន ០៩ រូប ៨០២០

១៣-១០-២០១២-ព្រះរាជក្រឹត្យ នស/រកត/១០១២/៩៣៩ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿង ឥស្សរិយយស សុវត្ថារា ថ្នាក់ មហាសេនា **Mr. Xie Ze Yu** អភិបាលក្រុងប៉ៃសឺ តំបន់ស្វយ័តជាំងក្វាងស៊ី នៃសាធារណរដ្ឋប្រជាមានិតចិន ៨០២១

១៣-១០-២០១២-ព្រះរាជក្រឹត្យ នស/រកត/១០១២/៩៤០ ស្តីពី ការតម្លើងឋានន្តរស័ក្តិ ថ្នាក់ ឧត្តមសេនីយ៍ត្រី ជូននាយនគរបាលជាន់ខ្ពស់ ក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា នៃ ក្រសួងមហាផ្ទៃ ៨០២២

១៣-១០-២០១២-ព្រះរាជក្រឹត្យ នស/រកត/១០១២/៩៤១ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿង ឥស្សរិយយស ជាតូបការ ចំពោះ នាយនគរបាល ថ្នាក់ ឧត្តមសេនីយ៍ ចំនួន ០៥ រូប នៃ ក្រសួងមហាផ្ទៃ ៨០២៣

១៣-១០-២០១២-ព្រះរាជក្រឹត្យ នស/រកត/១០១២/៩៤២ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿង ឥស្សរិយយស តាមលំដាប់ថ្នាក់ ចំពោះសប្បុរសជនជាតិបារាំង ចំនួន ០២ រូប និង មន្ត្រីនៃក្រសួងទេសចរណ៍ ០១ រូប ៨០២៤

១៣-១០-២០១២-ព្រះរាជក្រឹត្យ នស/រកត/១០១២/៩៤៣ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ ធិបឌិន្ទ ចំពោះសប្បុរសជនក្នុង និង ក្រៅប្រទេស ចំនួន ០៧ រូប ៨០២៥

១៣-១០-២០១២-ព្រះរាជក្រឹត្យ នស/រកត/១០១២/៩៤៤ ស្តីពី ការផ្ទេរបញ្ចូលឯកឧត្តម **តាន់ ម៉ន** ទៅក្នុងឋានន្តរស័ក្តិ ឧត្តមមន្ត្រីថ្នាក់លេខ ១ នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាលនៅក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ និង ដាក់ឱ្យចូលនិវត្តន៍ក្នុងក្របខ័ណ្ឌមុខងារសាធារណៈ ដោយរក្សាមុខតំណែងនយោបាយនៅដដែល ៨០២៦

១៣-១០-២០១២-ព្រះរាជក្រឹត្យ នស/រកត/១០១២/៩៤៥ ស្តីពី ការតែងតាំងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ដែលមានសមាសភាព ចំនួន ០៩ រូប ៨០២៧

II-រាជរដ្ឋាភិបាល

អនុក្រឹត្យ

១៩-១០-២០១២-អនុក្រឹត្យលេខ ១៨២ អនក្រ.បក ស្តីពី ការកាត់ចេញពីដីតម្រូវព្រៃឈើបំរុងទុកអចិន្ត្រៃយ៍របស់រដ្ឋ និង ពីដីក្រុមហ៊ុន ឬស្សី នូវផ្ទៃដីទំហំ ៩.២៧២ ហិកតា និង ធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ ដើម្បីធ្វើប្រទានកម្មជាកម្មសិទ្ធិ ជូនប្រជាពលរដ្ឋចំនួន ៣.៩៥១ គ្រួសារ ដែលបានកាន់កាប់ ប្រើប្រាស់ និង ដាំដុះជាក់ស្តែង នៅស្រុករតនៈមណ្ឌល ស្រុកបាណន់ និង ស្រុកបវេល ខេត្តបាត់ដំបង ៨០២៩

១៩-១០-២០១២-អនុក្រឹត្យលេខ ១៨៣ អនក្រ.បក ស្តីពី ការកាត់ដីទំហំ ១.៨៩៩ ហិកតា ចេញពីដីព្រៃសម្បទាន ក្រុមហ៊ុន សាមលីញ នូវផ្ទៃដីទំហំ ១.៤៥៩ ហិកតា និង ដីតម្រូវព្រៃដែលមានដីកាដកហូត លេខ ០១៧/០៦ អគខ.ដព នូវផ្ទៃដីទំហំ ៤៤០ ហិកតា និង ធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ ដើម្បីធ្វើប្រទានកម្មជាកម្មសិទ្ធិ ជូនប្រជាពលរដ្ឋ ចំនួន ៤៧៨ គ្រួសារ ដែលបាន កាន់កាប់ ប្រើប្រាស់ និង ដាំដុះជាក់ស្តែង នៅភូមិត្រពាំងឫស្សី ឃុំតំបែរ ស្រុកតំបែរ ខេត្តកំពង់ចាម ៨០៣៥

១៩-១០-២០១២-អនុក្រឹត្យលេខ ១៨៤ អនក្រ.បក ស្តីពី ការកាត់ដីចេញពីសម្បទានដីសេដ្ឋកិច្ចរបស់ក្រុមហ៊ុន ភាពីម៉ិច នូវផ្ទៃដីទំហំ ១.០២០ ហិកតា និង ធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ ដើម្បីធ្វើប្រទានកម្មជាកម្មសិទ្ធិ ជូនប្រជាពលរដ្ឋ ចំនួន ៧២៩ គ្រួសារ ដែលបានកាន់កាប់ ប្រើប្រាស់ និង ដាំដុះជាក់ស្តែង និង រក្សាទុកជាដីព្រៃបំរុងសម្រាប់សហគមន៍ព្រៃឈើ នៅឃុំក្រាំងលាវ ស្រុករលាប្អៀរ ខេត្តកំពង់ឆ្នាំង ៨០៣៨

១៩-១០-២០១២-អនុក្រឹត្យលេខ ១៨៥ អនក្រ.បក ស្តីពី ការកាត់ចេញពីដីតំបន់ដែនជម្រកសត្វព្រៃរនាមដូនសំ នូវផ្ទៃដីទំហំ ២.៨២៨ ហិកតា និង ធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ ដើម្បីធ្វើប្រទានកម្មជាកម្មសិទ្ធិ ជូនប្រជាពលរដ្ឋ ចំនួន ៤៤១ គ្រួសារ ដែលបានកាន់កាប់ ប្រើប្រាស់ និង ដាំដុះជាក់ស្តែង នៅភូមិគ្រួសក្រហម ឃុំអូររំដួល ស្រុកភ្នំព្រឹក ខេត្តបាត់ដំបង ៨០៤២

២២-១០-២០១២-អនុក្រឹត្យលេខ ១៨៦ អនក្រ.បក ស្តីពី ការកែសម្រួលមាត្រា ១ នៃអនុក្រឹត្យលេខ ១៥៦ អនក្រ.បក ស្តីពីប្រតិទិនឈប់សំរាកការងាររបស់មន្ត្រីរាជការ និយោជិត កម្មករ ប្រចាំឆ្នាំ ២០១៣ ៨០៤៥

២៣-១០-២០១២-អនុក្រឹត្យលេខ ១៨៧ អនក្រ.បក ស្តីពី ការផ្ទេរឥណទានថវិកា ៨០៤៨

០៣-១០-២០១២-អនុក្រឹត្យលេខ **១៤៨២** ដល់អនុក្រឹត្យលេខ **១៤៩៧** អនក្រ.តត ស្តីពី ការជូនមេដាយការងារ ៨០៥០

០៣-១០-២០១២-អនុក្រឹត្យលេខ ១៤៩៨ អនក្រ.តត ស្តីពី ការតែងតាំងមុខតំណែងនាយនគរបាលជាតិ ៨០៦៦

០៣-១០-២០១២-អនុក្រឹត្យលេខ ១៤៩៩ អនក្រ.តត ស្តីពី ការតែងតាំងមុខតំណែងនាយនគរបាលជាតិ ៨០៦៧

០៣-១០-២០១២-អនុក្រឹត្យលេខ ១៥០០ អនក្រ.តត ស្តីពី ការផ្ទេរបញ្ចូលទៅក្នុងក្របខ័ណ្ឌមន្ត្រីក្រមការក្រសួងមហាផ្ទៃ ៨០៦៨

០៣-១០-២០១២-អនុក្រឹត្យលេខ ១៥០១ អនក្រ.តត ស្តីពី ការដំឡើងឋានន្តរស័ក្តិនាយនគរបាលជាតិ ៨០៦៩

០៣-១០-២០១២-អនុក្រឹត្យលេខ ១៥០២ អនក្រ.តត ស្តីពី ការដំឡើងឋានន្តរស័ក្តិនាយនគរបាលជាតិ ៨០៧១

០៣-១០-២០១២-អនុក្រឹត្យលេខ ១៥០៣ អនក្រ.តត ស្តីពី ការជូនមេដាយមុនីសារាភ័ណ្ឌ ៨០៧២

០៣-១០-២០១២-អនុក្រឹត្យលេខ **១៥០៤** ដល់អនុក្រឹត្យលេខ **១៥៤៤** អនក្រ.តត ស្តីពី ការជូនមេដាយការងារ ៨០៧៣

III-ការចារបណ្ណាក្រសួង

ទីស្តីការរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

២៤-៦-២០១១ -លិខិតបញ្ជាក់លេខ ៣៩៤២ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ម៉ូឌមេឌា (ខេមបូឌា) ខូ អិលធីឌី** ៨១១៤

២៤-៦-២០១១ -លិខិតបញ្ជាក់លេខ ៣៩៤៣ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ត្រេឌីត ប៉ូរ្ស ហូលឌីង (ខេមបូឌា) អិលធីឌី** ៨១១៦

២៧-៦-២០១១ -លិខិតបញ្ជាក់លេខ ៣៥៦៤ ពណ.ចបព ស្ដីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **អ៊ិតឆេន ស៊ីល្វូសិន (ខេមបូឌា)** ៨១១៧

២៧-៦-២០១១ -លិខិតបញ្ជាក់លេខ ៣៥៨១ ពណ.ចបព ស្ដីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **គ្រាន ហ៊ីខ អ៊ិនវេសមេន & អ៊ីមនិច** ៨១១៩

២៧-៦-២០១១ -លិខិតបញ្ជាក់លេខ ៣៥៨២ ពណ.ចបព ស្ដីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ឌីលីស សេហ្សឺរ អិលធីឌី** ៨១២១

២៧-៦-២០១១ -លិខិតបញ្ជាក់លេខ ៣៥៨៣ ពណ.ចបព ស្ដីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ឆៀន ហ៊ី (ខេមបូឌា) គ្រុប** ៨១២៣

២៧-៦-២០១១ -លិខិតបញ្ជាក់លេខ ៣៥៩២ ពណ.ចបព ស្ដីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **រ៉ាមី រេនៈ ខនស្ត្រាក់សិន** ៨១២៥

២៧-៦-២០១១ -លិខិតបញ្ជាក់លេខ ៣៥៩៣ ពណ.ចបព ស្ដីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ឌូ ប៉ែល ផ្លាស** ៨១២៧

២៧-៦-២០១១ -លិខិតបញ្ជាក់លេខ ៣៥៩៤ ពណ.ចបព ស្ដីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **អេស៊ា សាមគ្គី ខនស្ត្រាក់សិន គ្រុប** ៨១២៩

២៧-៦-២០១១ -លិខិតបញ្ជាក់លេខ ៣៥៩៥ ពណ.ចបព ស្ដីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ជី តិកឹល អ៊ីមផ្លូយមេន អេជេនស៊ី** ៨១៣១

២៨-៦-២០១១ -លិខិតបញ្ជាក់លេខ ៣៦០៧ ពណ.ចបព ស្ដីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ហ្វ៊ីត ឡៀវ៉ានណា** ៨១៣៣

ព្រះរាជក្រឹត្យ

នស/រកត/១០១២/៨៣៦

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រត្តនខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រម លេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ ជស/រកត/០៣០០/១១៦ ចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០០០ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល
- បានទ្រង់យល់ព្រះរាជក្រម លេខ នស/រកម/០១៩៦/១៤ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងព័ត៌មាន
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១: ដំឡើងឋានន្តរស័ក្តិជូនមន្ត្រីរាជការ ចំនួន ០២ រូប ពីឋានន្តរស័ក្តិវរមន្ត្រី ទៅឋានន្តរស័ក្តិឧត្តមមន្ត្រី នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល របស់ក្រសួងព័ត៌មាន ៖

ល.រ	គោត្តមនាម និង នាម	ភេទ	ក្របខ័ណ្ឌ ឋានន្តរស័ក្តិ និង ថ្នាក់	
			ចាស់	ស្នើសុំ
១	សោម សារុន	ប	ក.២.៣	ក.១.៤
២	អ៊ិន ផាយ	ប	ក.២.៤	ក.១.៥

មាត្រា ២: សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ។

មាត្រា ៣: ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

៣៧-១៦១០.៩៤៦

លេខៈ ៩០៧ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ២០១២
[illegible] ប្រតិភូរាជរដ្ឋាភិបាល
[illegible] សុខា

ធ្វើនៅព្រះបរមរាជវាំង . ថ្ងៃទី ១៦ ខែ តុលា ឆ្នាំ ២០១២

ព្រះរាជក្រឹត្យ

នស/រកត/១០១២/៩៣៤

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែកញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៥០១/១៧៨ ចុះថ្ងៃទី ២២ ខែឧសភា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១ : ដំឡើងឋានន្តរស័ក្តិថ្នាក់ **ឧត្តមសេនីយ៍ទោ** ជូនលោកឧត្តមសេនីយ៍ត្រី **លឹម ឡុង** អត្តលេខ ០៩៦៥ នៃក្របខ័ណ្ឌនគរបាលជាតិកម្ពុជា ក្រសួងមហាផ្ទៃ ។

មាត្រា ២ : សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៣ : ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

ពរក.១៤១០.៩៤៤

លេខ ៦១៩ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ... ខែ ... ឆ្នាំ២០១២
...រាជរដ្ឋាភិបាល
... សុខា

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១៤ ខែ តុលា ឆ្នាំ ២០១២

ព្រះរាជក្រឹត្យ

នស/រកត/១០១២/៩៣៦

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

-បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានទ្រង់យល់ព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៦ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសុខាភិបាល

-បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១២ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងអភិវឌ្ឍន៍ជនបទ

-បានទ្រង់យល់ព្រះរាជក្រឹត្យលេខ ជស/រកត/០៣០០/១១៦ ចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០០០ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល

-បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា១: ដំឡើងថ្នាក់ប្រចាំឆ្នាំជូនមន្ត្រីរាជការចំនួន ០៦ រូប ក្នុងឋានន្តរស័ក្តិឧត្តមមន្ត្រី នៃក្របខណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល របស់ក្រសួង ស្ថាប័ន ចាប់ពីថ្ងៃទី ១៣ ខែ មេសា ឆ្នាំ ២០១២ ៖

ក្រសួងសុខាភិបាល				
ល.រ	នាម និង គោត្តនាម	ភេទ	ឋានន្តរស័ក្តិ និងថ្នាក់ចាស់	ឋានន្តរស័ក្តិ និងថ្នាក់ស្នើសុំ
១	អ៊ឹង តិរុន	ប	ពីឧត្តមមន្ត្រី ថ្នាក់លេខ ៤	ទៅឧត្តមមន្ត្រី ថ្នាក់លេខ ៣
២	[illegible] លន់	ប	ពីឧត្តមមន្ត្រី ថ្នាក់លេខ ៤	ទៅឧត្តមមន្ត្រី ថ្នាក់លេខ ៣
៣	[illegible]សិរីរម្យ	ប	ពីឧត្តមមន្ត្រី ថ្នាក់លេខ ៦	ទៅឧត្តមមន្ត្រី ថ្នាក់លេខ ៥
ក្រសួងអភិវឌ្ឍន៍ជនបទ				
[illegible]	[illegible] សុផល	ប	ពីឧត្តមមន្ត្រី ថ្នាក់លេខ ២	ទៅឧត្តមមន្ត្រី ថ្នាក់លេខ ១

ROYAUME DU CAMBODGE LE MINISTRE DU PALAIS ROYAL ក្រសួងព្រះបរមរាជវាំង

២	**ជា សំណាង**	ប	ពីឧត្តមមន្ត្រី ថ្នាក់លេខ ៤	ទៅឧត្តមមន្ត្រី ថ្នាក់លេខ ៣
៣	**ចាន់ ដារ៉ុន**	ប	ពីឧត្តមមន្ត្រី ថ្នាក់លេខ ៦	ទៅឧត្តមមន្ត្រី ថ្នាក់លេខ ៥

មាត្រា២: បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

មាត្រា៣: សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលអនុវត្តឲ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ។

មាត្រា៤: ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ

នរោត្តម សីហមុនី

ពរស.១៤១០.៩៤៦

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១៣ ខែ តុលា ឆ្នាំ ២០១២

លេខ: ៩០៣ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ ១៣ ឆ្នាំ២០១២

អគ្គលេខាធិការរងទីស្តីការគណៈរដ្ឋមន្ត្រី

សយ សុខា

ព្រះរាជក្រឹត្យ

នស/រកត/១០១២/៨៣៧

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ០៦/នស/១៩៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៩ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងធម្មការ និងសាសនា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១ : ត្រូវបានបញ្ចប់មុខតំណែងឯកឧត្តម **ម៉ៅ រិទ្ធីថា** ពីអនុរដ្ឋលេខាធិការក្រសួងធម្មការ និងសាសនា ។

មាត្រា ២ : បទបញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងព្រះរាជក្រឹត្យនេះត្រូវចាត់ទុកជានិរាករណ៍ ។

មាត្រា ៣ : សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ។

មាត្រា ៤ : ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

លេខ [illegible] ០១ប.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ២០១២
[illegible] រាជរដ្ឋាភិបាល

៣៧៧.១៤១០.៨៤៧

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១៣ ខែ តុលា ឆ្នាំ ២០១២

សយ សុខា

ព្រះរាជក្រឹត្យ

នស/រកត/១០១២/៩៣៨

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

ប្រោសព្រះរាជទាន

ចំពោះ

ព្រះសង្ឃ សប្បុរសជន និងមន្ត្រីរាជការ ចំនួន០៩រូប ដែលមានស្នាដៃល្អ និងគុណបំណាច់
ក្នុងការចូលរួមជួយកសាងសមិទ្ធផលនានាក្នុងខេត្តព្រះសីហនុ ទទួលបានលទ្ធផលល្អប្រសើរ កន្លងមក

នូវ

ក-គ្រឿងឥស្សរិយយស មុនីសារាភ័ណ្ឌ ថ្នាក់ មហាសេរីវឌ្ឍន៍

១-ព្រះតេជគុណ ឆន់ សាវ៉ន
២-លោក គីម ហៀង

ខ-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេនា

១-លោកស្រី កែប សម្បត្តិ
២-លោក ឈេង ធិ
៣-វរសេនីយ៍ឯក ខៀវ សំណាង អត្តលេខ ០១២៥៣៨
៤-អ្នកស្រី ថន ផល្លា
៥-លោក សៀក ហុក
៦-វរសេនីយ៍ឯក ជា ទុទ្ធី អត្តលេខ០១៦៥៨៨
៧-វរនាវីឯក ឡឿន ដារ៉ានី អត្តលេខ ០១០៥៦៧

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

៣៧.០៤១០.៩៤៨

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១៣ ខែ តុលា ឆ្នាំ ២០១២

លេខ ៩០០ ប.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី១៩ ខែ ១០ ឆ្នាំ២០១២
អគ្គលេខាធិការ[illegible]រាជរដ្ឋាភិបាល

សយ សុខា

ព្រះរាជក្រឹត្យ

នស/រកត/១០១២/៩៣៥

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា
សិរីវិបុលា ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

ប្រោសព្រះរាជទាន

នូវ

គ្រឿងឥស្សរិយយស សុវត្ថារា ថ្នាក់ មហាសេនា

ចំពោះ

Mr. Xie Ze Yu
អភិបាលក្រុងប៉ៃសឺ តំបន់ស្វ័យតជាំងក្វាងស៊ី នៃសាធារណរដ្ឋប្រជាមានិតចិន
ដែលបានជួយឧបត្ថម្ភម៉ាស៊ីនបូមទឹក ចំនួន ៦០គ្រឿង គោយន្តខ្នាតធំ ចំនួន ៣០គ្រឿង
និងគោយន្តខ្នាតតូចចំនួន ៣០គ្រឿង ដល់សាលាខេត្តកំពត

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

៣៧៧-១២១០-៩៤៩

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១៧ ខែ តុលា ឆ្នាំ ២០១២

លេខៈ ៤៩៩ ប.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ១៨ ខែ ១១ ឆ្នាំ២០១២
អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល

សយ សុខា

ព្រះរាជក្រឹត្យ

នស/រកត/១០១២/៩៤០

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៥០១/១៧៨ ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ២០០១ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១ ៖ ដំឡើងឋានន្តរស័ក្តិថ្នាក់ **ឧត្តមសេនីយ៍ត្រី** ជូននាយនគរបាលជាន់ខ្ពស់ ក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា នៃក្រសួងមហាផ្ទៃ ៖

១- លោកវរសេនីយ៍ឯក **ម៉ៅ សារី** អត្តលេខ ០៧៣១
២- លោកស្រីវរសេនីយ៍ឯក **ឈាង គឹមស៊ុន** អត្តលេខ ០៨១៣
៣- លោកវរសេនីយ៍ឯក **គង់ ពុទ្ធី** អត្តលេខ ០១២៩៧
៤- លោកវរសេនីយ៍ឯក **តិន ផាណិត** អត្តលេខ ០១១៦៤
៥- លោកវរសេនីយ៍ឯក **សៀង សុចត្ថិ** អត្តលេខ ៥៤៨៦៦

មាត្រា ២ ៖ បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា ៣ ៖ សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តអោយបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៤ ៖ ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

រ.ល.១៤១០.៩៥០

លេខ ៩០២ ច.ល
ជម្រាបជូនចែក
រាជធានីភ្នំពេញ ថ្ងៃទី ១៣ ខែ តុលា ឆ្នាំ២០១២
អគ្គលេខាធិការនៃទីស្តីការគណៈរដ្ឋមន្ត្រីរាជរដ្ឋាភិបាល

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១៧ ខែ តុលា ឆ្នាំ ២០១២

ព្រះរាជអគ្គលេខាធិការដ្ឋាន ...សុខា

ព្រះរាជក្រឹត្យ

នស/រកត/១០១២/៩៤១

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

ប្រោសព្រះរាជទាន

ចំពោះ

នាយនគរបាល ថ្នាក់ឧត្តមសេនីយ៍ ចំនួន០៥រូប នៃក្រសួងមហាផ្ទៃ ដែលបានខិតខំប្រឹងប្រែងបំពេញភារកិច្ច
ថែរក្សាការពារសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ សុវត្ថិភាព និងស្ថេរភាពសង្គម
ដើម្បីបម្រើផលប្រយោជន៍របស់ប្រទេសជាតិ និងប្រជាពលរដ្ឋបានល្អប្រសើរ

នូវ

គ្រឿងឥស្សរិយយស ជាតូបការ

១- ឯកឧត្តម ឧត្តមសេនីយ៍ឯក	**ម៉ៅ ម៉ុនណារិន**	អត្តលេខ ០០៣៦
២- ឯកឧត្តម ឧត្តមសេនីយ៍ឯក	**ឯម សំណាង**	អត្តលេខ ០៥៧៥
៣- ឯកឧត្តម ឧត្តមសេនីយ៍ឯក	**សរ សិទ្ធិ**	អត្តលេខ ៦១៧៨៨
៤- ឯកឧត្តម ឧត្តមសេនីយ៍ឯក	**កែវ សុទ្ធា**	អត្តលេខ ០៣៩៨
៥- ឯកឧត្តម ឧត្តមសេនីយ៍ឯក	**មៀច សុផាន់ណា**	អត្តលេខ ០២៥២ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

ចារ.១៤១០.៩៤១

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១៣ ខែ តុលា ឆ្នាំ ២០១២

លេខ: ៩៩៤០.ល
ជូនជ្រាបនិងចែក
រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ តុលា ឆ្នាំ២០១២
អគ្គលេខាធិការរាជរដ្ឋាភិបាល
សយ សុខា

ព្រះរាជក្រឹត្យ

នស/រកត/១០១២/៩៤៤

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

ប្រោសព្រះរាជទាន

ចំពោះ

សប្បុរសជនជនជាតិបារាំង ចំនួន០២រូប និងមន្ត្រីនៃក្រសួងទេសចរណ៍ ០១រូប ដែលបានរួមកិច្ចសហប្រតិបត្តិការជាមួយរាជរដ្ឋាភិបាល បានចំណាយធនធានផ្ទាល់ខ្លួនជាច្រើនក្នុងការសាងសង់អគារសិក្សាថ្មី របស់សាលាសណ្ឋាគារ និងទេសចរណ៍ ប៉ូលឌុយប្រ៊ូល ស្ថិតនៅខេត្តសៀមរាប ដើម្បីរួមចំណែកក្នុងការអភិវឌ្ឍន៍ធនធានមនុស្សលើវិស័យទេសចរណ៍ស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល

នូវ

ក-គ្រឿងឥស្សរិយយស សហមេត្រី ថ្នាក់ មហាសេរីវឌ្ឍន៍
លោក ប៉ូល ឌុយប្រ៊ូល (Paul Dubrule)

ខ-គ្រឿងឥស្សរិយយស សហមេត្រី ថ្នាក់ មហាសេនា
លោក ហ្សេរ៉ាល់ ហ៊ូហ្គាឌី (Gerald Hougardy)

គ-គ្រឿងឥស្សរិយយស មុនីសារាភ័ណ្ឌ ថ្នាក់ មហាសេនា
លោក ខែន រតនា

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

[illegible]

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១៧ ខែ តុលា ឆ្នាំ ២០១២

លេខៈ ៩៧៧ច.ល
ដើម្បី[illegible]ចែក
រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ២០១២
[illegible]រាជរដ្ឋាភិបាល
[illegible] សុខា

ព្រះរាជក្រឹត្យ

នស/រកត/១០១២/៩៤៣

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

ប្រោសព្រះរាជទាន

ចំពោះ

សប្បុរសជនក្នុងនិងក្រៅប្រទេស ចំនួន០៧រូប មានគុណបំណាច់និងស្នាដៃល្អក្នុងការជួយកសាង
សមិទ្ធផលនានារួមចំណែកក្នុងការអភិវឌ្ឍវិស័យអប់រំនិងសាសនាឥស្លាម នៅក្នុងប្រទេសកម្ពុជា

នូវ

គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ ធិបឌិន្ទ

១-លោក ហូសេន មហាម៉ាត់ហ្វារីត
២-លោក Abdullah Al Ansari
៣-លោក DatoHajiOthman binMustapha
៤-លោក HajiMohdNoor dinBinIbrahim
៥-លោក DatoDr.AbHalimbintamuri
៦-លោក HajiAhmadAzam abd Rahman
៧-លោក លី សារឿន

ព្រះហស្តលេខា និងព្រះរាជលញ្ជករ
នរោត្តម សីហមុនី

ពរស.១៤.១០.៩៤៣

លេខៈ ៤៩៦ច.ល
ថតចំលងចែកចាយ

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១៣ ខែ តុលា ឆ្នាំ ២០១២ រាជធានីភ្នំពេញ ថ្ងៃទី ១៨ ខែ ១០ ឆ្នាំ២០១២
អគ្គលេខាធិការនៃទីស្តីការគណៈរដ្ឋមន្ត្រី

សយ សុខា

ព្រះរាជក្រឹត្យ

នស/រកត/១០១២/៩៤៤

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានតួមិជាតិសាសនា រតនខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១០៥/០០៣ ចុះថ្ងៃទី ១៧ ខែ មករា ឆ្នាំ ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/២៤ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ ជស/រកត/០៣០០/១១៦ ចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០០០ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១ : ផ្ទេរបញ្ចូលឯកឧត្តម **ភាន់ ម៉ន** ទៅក្នុងឋានន្តរស័ក្តិ ឧត្តមមន្ត្រី ថ្នាក់លេខ ១ នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាលនៅក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងដាក់ឱ្យចូលនិវត្តន៍ក្នុងក្របខ័ណ្ឌមុខងារសាធារណៈ ចាប់ពីថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ២០១២ ដោយរក្សាមុខដំណែងនយោបាយនៅដដែល រហូតមានការសម្រេចជាថ្មីពីរាជរដ្ឋាភិបាល។

មាត្រា ២: បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

មាត្រា ៣ : សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ។

មាត្រា ៤ : ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

ករល. ០៤១០. ៩៤៤

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ ... ៥០.ល
ដើម្បីឡាយព្រះហស្តលេខា ... ១៣ ... ឆ្នាំ២០១២
នាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាល

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១៣ ខែ តុលា ឆ្នាំ ២០១២

... សុខា

ព្រះរាជក្រឹត្យ

យើង

នស / រកត / ១០១២ / ៩៤៥

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ **នរោត្តម សីហមុនី**
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

-បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
-បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស / រកត / ០៩០៨ / ១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
-បានទ្រង់យល់ព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
-បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/១២៩៧/០៦ ចុះថ្ងៃទី២៦ ខែធ្នូ ឆ្នាំ១៩៩៧ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ
-បានទ្រង់យល់ព្រះរាជក្រមលេខនស/រកម/០៩០២/០១៧ ចុះថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០០២ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីច្បាប់វិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ
-បានទ្រង់យល់ព្រះរាជក្រមលេខនស/រកម/០៦០៦/០១៩ ចុះថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០០៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីវិសោធនកម្មមាត្រា១៣ថ្មីនៃច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ
-បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៧១១/០១៣ ចុះថ្ងៃទី៤ ខែកក្កដា ឆ្នាំ២០១១ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ
-បានទ្រង់យល់ព្រះរាជក្រមលេខ ជស/រកម/១១៩៧/០៧ ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ១៩៩៧ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីគណបក្សនយោបាយ
-បានទ្រង់យល់សម័យប្រជុំរដ្ឋសភាជាវិសាមញ្ញ នីតិកាលទី៤ នាថ្ងៃព្រហស្បតិ៍ទី១១ ខែតុលា ឆ្នាំ២០១២ ស្តីពីលទ្ធផលនៃការបោះឆ្នោតជ្រើសតាំងប្រធាន អនុប្រធាន និងសមាជិកនៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតចំនួនឲ្យប
-បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១ : ត្រូវបានតែងតាំងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ដែលមានសមាសភាពដូចតទៅ៖

១-ឯកឧត្តម	**អ៊ឹម សូស្ដី**	ប្រធាន
២-លោកជំទាវ	**ស៊ីន ជុំបូ**	អនុប្រធាន
៣-ឯកឧត្តម	**ហាវ៉ាណា ស៊ីទិល័យ**	សមាជិក
៤-ឯកឧត្តម	**មាន សាធិ**	សមាជិក
៥-ឯកឧត្តម	**ឯម សុផាត**	សមាជិក

ROYAUME DU CAMBODGE * LE MINISTERE DU PALAIS ROYAL
ក្រសួងព្រះបរមរាជវាំង

៦-ឯកឧត្តម **សោម ច័ន្ទឌីណា** សមាជិក

៧-ឯកឧត្តម **ម៉ៅ សុភារិទ្ធ** សមាជិក

៨-ឯកឧត្តម **ស៊ិន ឌីម** សមាជិក

៩-ឯកឧត្តម **សោ សុភរី** សមាជិក។

មាត្រា ២ : សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តឲ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ។

មាត្រា ៣ : បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

មាត្រា ៤ : ព្រះរាជក្រឹត្យនេះចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ

នរោត្តម សីហមុនី

ចរល.១២១០.៥៥៥

លេខៈ ៨៩០០ប.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ តុលា ឆ្នាំ២០១២

ធ្វើនៅព្រះបរមរាជវាំង . ថ្ងៃទី ១៣ ខែ តុលា ឆ្នាំ ២០១២

អគ្គលេខាធិការរងទីស្តីការគណៈរដ្ឋមន្ត្រី ... ទីស្តីការគណៈរដ្ឋាភិបាល

ស៊យ សុខា

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ:១៨២ .អនក្រ.បក

អនុក្រឹត្យ
ស្តីពី
ការកាត់ចេញពីដីគម្របព្រៃឈើ បម្រុងទុកអចិន្ត្រៃយ៍របស់រដ្ឋ និងពីដីក្រុមហ៊ុន ឬស្សី នូវផ្ទៃដីទំហំ ៩២៧២ ហិកតា និងធ្វើអនុបយោគ ជាដីឯកជនរបស់រដ្ឋ ដើម្បីធ្វើប្រទានកម្ម ជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ចំនួន ៣៥៥១ គ្រួសារ ដែលបាន កាន់កាប់ ប្រើប្រាស់ និងដាំដុះជាក់ស្តែង នៅស្រុក រតនៈមណ្ឌល ស្រុក បាណន់ និងស្រុកបវេល ខេត្តបាត់ដំបង

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២នសចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឲ្យ ប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យ ប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឲ្យ ប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០២/០១៦ ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០២ ដែលប្រកាសឲ្យ ប្រើច្បាប់ស្តីពីព្រៃឈើ
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៨០៦/៣៣៩ ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០០៦ ស្តីពីគោលការណ៍ និងបញ្ញត្តិអន្តរកាលនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ
- បានឃើញអនុក្រឹត្យលេខ៦២ អនក្រ.បក ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

- បានឃើញអនុក្រឹត្យលេខ១៧ អនក្រ.បក ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ៨៨ អនក្រ.បក ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០០០ ស្តីពីការបង្កើតក្រុមប្រឹក្សាគោលនយោបាយដីធ្លី
- បានឃើញអនុក្រឹត្យលេខ១១៨ អនក្រ.បក ចុះថ្ងៃទី០៧ ខែតុលា ឆ្នាំ២០០៥ ស្តីពីការគ្រប់គ្រងដីរដ្ឋ
- បានឃើញអនុក្រឹត្យលេខ១៤៦ អនក្រ.បកចុះថ្ងៃទី២៧ខែធ្នូ ឆ្នាំ២០០៥ ស្តីពីសម្បទានដីសេដ្ឋកិច្ច
- បានឃើញសារាចរលេខ ០២ សរ ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០០៧ ស្តីពីការកាន់កាប់ដីរដ្ឋដោយខុសច្បាប់
- តាមសំណើលេខ ១៣២១ របប ចុះថ្ងៃទី០៥ ខែតុលា ឆ្នាំ២០១២ របស់គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តបាត់ដំបង
- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

សម្រេច

មាត្រា ១..

ត្រូវបានកាត់ចេញពីដីគម្របព្រៃឈើបម្រុងទុកអចិន្ត្រៃយ៍ និងពីដី ក្រុមហ៊ុន ឫស្សី នូវផ្ទៃដីទំហំ ៩២៧២ ហិកតា និងធ្វើអនុបយោគ ជាដីឯកជនរបស់រដ្ឋ នៅខេត្តបាត់ដំបង ស្ថិតនៅក្នុងភូមិ ឃុំ ស្រុក ដូចខាងក្រោម៖

១.១. ផ្ទៃដីទំហំ ១៣៥៤ ហិកតា នៅភូមិអូរដា ឃុំផ្លូវមាស ស្រុក រតនៈមណ្ឌល តាមប្រព័ន្ធកូអរដោណេ Project UTM Zone 48N Datum wgs 1984 និងមាននិយាមកាដូចកំណត់ក្នុងផែនទីឧបសម្ព័ន្ធ (1) នៃអនុក្រឹត្យនេះ

១.២. ផ្ទៃដីទំហំ ៤១៩៣ ហិកតា នៅភូមិបុះខ្នុរ ឃុំចែងមានជ័យ ស្រុក បាណន់ តាមប្រព័ន្ធកូអរដោណេ Project UTM Zone 48N Datum wgs 1984 និងមាននិយាមកាដូចកំណត់ក្នុងផែនទីឧបសម្ព័ន្ធ (2) នៃអនុក្រឹត្យនេះ

១.៣. ផ្ទៃដីទំហំ ១៦៨១ ហិកតា នៅភូមិស្លាប៉ោង ឃុំតាគ្រាម ស្រុក បាណន់

១.៤. ផ្ទៃដីទំហំ ២០៤៤ ហិកតា នៅភូមិទំនប់តាកួន ឃុំឃ្លាំងមាស ស្រុកបវេល

ចំណុច ១.៣ និង១.៤ ខាងលើ តាមប្រព័ន្ធកូអរដោណេ Project UTM Zone 48N Datum wgs 1984 និងមាននិយាមកាដូចកំណត់ក្នុងផែនទីឧបសម្ព័ន្ធ (3) នៃអនុក្រឹត្យនេះ

មាត្រា ២..

ត្រូវបានប្រគល់អាណត្តិកាន់កាប់ និងបែងចែកដីឯកជនរបស់រដ្ឋដូចមានចែងក្នុងមាត្រា១ ជូនគណៈកម្មាធិការ គ្រប់គ្រងដីរដ្ឋខេត្តបាត់ដំបង ដើម្បីធ្វើការគ្រប់គ្រង និងប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋដែលបានកាន់កាប់ ប្រើប្រាស់ និងដាំដុះជាក់ស្តែងចំនួន ៣៥៥១ គ្រួសារ នៅក្នុងភូមិដូចខាងក្រោម៖

- ប្រទានកម្មជាកម្មសិទ្ធជូនប្រជាពលរដ្ឋ ចំនួន ១៣៨៤ គ្រួសារ នៅភូមិអូរដា ឃុំផ្លូវមាស ស្រុករតនៈមណ្ឌល

- ប្រទានកម្មជាកម្មសិទ្ធជូនប្រជាពលរដ្ឋចំនួន **១២៥០** គ្រួសារ នៅភូមិបុះខ្នុរ ឃុំចែងមានជ័យ ស្រុក បាណន់
- ប្រទានកម្មជាកម្មសិទ្ធជូនប្រជាពលរដ្ឋចំនួន **៥៧៣** គ្រួសារ នៅភូមិស្លារប៉ាង ឃុំតាគ្រាម ស្រុក បាណន់
- ប្រទានកម្មជាកម្មសិទ្ធជូនប្រជាពលរដ្ឋចំនួន**៣៨៤** គ្រួសារ នៅភូមិទំនប់តាកួន ឃុំឃ្លាំងមាស ស្រុក បវេល

មាត្រា ៣ ..

ក្នុងពេលដំណើរការវាស់វែង និងបែងចែកជាក់ស្តែង គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តបាត់ដំបង ត្រូវកាត់ចេញនូវចំណែកដីមួយចំនួនសមស្របដើម្បីរក្សាទុកសម្រាប់បម្រើផលប្រយោជន៍សាធារណៈ ទាំងសម្រាប់ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងសង្គម នៅក្នុងមូលដ្ឋាន។

មាត្រា ៤ ..

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយពីអនុក្រឹត្យនេះត្រូវចាត់ទុកជានិរាករណ៍ ។

មាត្រា ៥..

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងអភិបាលនៃគណៈអភិបាលខេត្តបាត់ដំបង ត្រូវអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៨ ខែ ១១ ឆ្នាំ២០១២

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល៖

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការ រាជរដ្ឋាភិបាល*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា*
- *អគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិដោះស្រាយវិវាទដីធ្លី*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ៥*
- *រាជកិច្ច*
- *ឯកសារកាលប្បវត្តិ*

ឧបសម្ព័ន្ធ ៣

ឧបសម្ព័ន្ធនៃអនុក្រឹត្យលេខ ១៧៤ អនក្រ.បក ចុះថ្ងៃទី...១៩...ខែ.តុលា......ឆ្នាំ២០១២ ស្តីពីការកាត់ចេញពីដីព្រៃ ... ជាសម្បត្តិសាធារណៈរបស់រដ្ឋ និងពីដីព្រៃ ... ផ្ទៃដីសរុប ... ហិកតា និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ ដើម្បីផ្តល់ប្រគល់កម្មសិទ្ធិជូនប្រជាពលរដ្ឋចំនួន ៣៥៥០ គ្រួសារ ដែលបានកាន់កាប់ អាស្រ័យផល និងរស់នៅជាក់ស្តែង នៅស្រុកគគរៈមណ្ឌល ស្រុកបាកាន និងស្រុកក្រគរ ខេត្តពោធិ៍សាត់



ចំណុចនិយាមកា					
ល.រ	X	Y	ល.រ	X	Y
1	272137	1447629	24	264540	1442021
2	272129	1447031	25	264972	1442722
3	271989	1446356	26	265750	1442712
4	271894	1445557	27	265397	1443710
5	271938	1443982	28	265818	1443706
6	272451	1443982	29	265937	1445302
7	272451	1442070	30	267226	1445336
8	273095	1442128	31	267245	1446879
9	273781	1442062	32	269024	1447370
10	273961	1440375	33	270877	1447668
11	273061	1440380	34	270699	1445640
12	271709	1439830	35	271007	1445504
13	271698	1439627	36	271029	1443596
14	269519	1439603	37	270845	1440965
15	268504	1439298	38	268979	1440852
16	268282	1439076	39	268600	1440777
17	267472	1438581	40	268511	1441269
18	266541	1438683	41	268125	1441862
19	267090	1441167	42	267477	1442331
20	265667	1441602	43	268486	1445191
21	265543	1441249	44	269047	1445783
22	264971	1441629	45	269418	1445947
23	264872	1442040	46	270663	1445782

កម្មវត្ថុសម្គាល់

អនុក្រឹត្យលេខ ១០៧ អនក្រ.បក ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១២ ផ្ទៃដីទំហំ១៣៣០០ហិកតា

ឧបសម្ព័ន្ធ ២

ឧបសម្ព័ន្ធនៃអនុក្រឹត្យលេខ...អនក្រ.បក ចុះថ្ងៃទី...២៩....ខែ..តុលា.....ឆ្នាំ២០១២ ស្តីពីការកាត់ចេញពីដីគម្របព្រៃឈើ ចំណុះអចលនទ្រព្យរបស់រដ្ឋ និងពីដីព្រៃលិចទឹក ឬស្សី ផ្ទៃដីទំហំ៤២៧២ហិកតា និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ ដើម្បីធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋចំនួន ៣៥៥០គ្រួសារ ដែលបានកាន់កាប់ ប្រើប្រាស់ និងរស់នៅជាក់ស្តែង នៅស្រុកកោះក្រឡ ស្រុកបាណន់ និងស្រុកបវេល ខេត្តបាត់ដំបង



ចំណុចដីយោងការ					
ល.រ	X	Y	ល.រ	X	Y
1	294686	1421216	24	286743	1414044
2	295534	1417762	25	286801	1414359
3	295310	1417561	26	286662	1415027
4	295501	1415287	27	286935	1415975
5	295268	1415398	28	286561	1416081
6	295267	1415260	29	286917	1416685
7	293838	1415283	30	286673	1417622
8	293551	1415452	31	286885	1418192
9	293607	1415146	32	287582	1418712
10	293334	1415082	33	287697	1419112
11	292934	1414923	34	288007	1419271
12	292729	1414911	35	288250	1418951
13	292675	1415162	36	289196	1418632
14	292065	1415085	37	289645	1418522
15	291864	1414715	38	291133	1418989
16	291868	1414367	39	291138	1419324
17	291452	1414348	40	292657	1420047
18	291503	1414120	41	294469	1420552
19	289753	1413674	42	294499	1420668
20	289715	1413836	43	294537	1420876
21	289049	1413811	44	294675	1421041
22	288564	1414304	45	294589	1421022
23	287669	1414291	46	294449	1421221





ប្រព័ន្ធអរដោនេ:
តំបន់ទី : 48N
ចំណោលផែនទី : UTM
ទិន្នន័យយោង : WGS1984

ប្រភពទិន្នន័យ:
ព្រំប្រទល់: នាយកដ្ឋានភូមិសាស្ត្រ
គំរបព្រៃ: រដ្ឋបាលព្រៃឈើ ឆ្នាំ ២០០២

ព្រៃស្រោង
ព្រៃពាក់កណ្តាលស្រោង
ដីមិនមែនព្រៃ
ព្រំប្រទល់ដីស្នើសុំ

ឧបសម្ព័ន្ធ ១

ឧបសម្ព័ន្ធនៃអនុក្រឹត្យលេខ...១៧៤ អនក្រ.បក...ចុះថ្ងៃទី...២៧...ខែ...តុលា...ឆ្នាំ២០១២ ស្តីពីការកាត់ចេញពីដីតំបន់ព្រៃឈើ ទុកជាសម្បត្តិរដ្ឋ និងពីដីព្រៃ ... ទំហំ ២០៧២ហិកតា និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ ដើម្បីធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋចំនួន ៣៥៤០គ្រួសារ ដែលរស់នៅកាន់កាប់ ប្រើប្រាស់ និងជាជម្រកផ្ទាល់ នៅស្រុករតនមណ្ឌល ស្រុកបាណន់ និងស្រុកបវេល ខេត្តបាត់ដំបង



ចំណុចនិយាមកា					
ល.រ	X	Y	ល.រ	X	Y
1	260646	1414204	19	258642	1408861
2	260492	1413726	20	257953	1408925
3	260834	1413556	21	257500	1409362
4	260878	1413133	22	257094	1409764
5	260816	1412048	23	256932	1410022
6	260592	1411754	24	257174	1410519
7	260880	1410845	25	257223	1411089
8	261143	1410677	26	257148	1411365
9	260953	1410108	27	257532	1411546
10	260547	1410022	28	257668	1411838
11	260179	1409493	29	257317	1412142
12	260240	1410051	30	257472	1412677
13	259483	1410120	31	257913	1412812
14	259505	1409706	32	258450	1413215
15	259365	1409466	33	259385	1413662
16	258996	1409261	34	259471	1413988
17	259141	1408191	35	260130	1414041
18	258651	1408522			

N W E S

មាត្រដ្ឋាន 1:50,000

1 0.5 0 1

Kilometers

ដីមិនមែនព្រៃ

ព្រំប្រទល់ដីស្នើសុំ

ព្រំប្រទល់ដីភ្នំ

(ផ្ទៃដីភ្នំសរុបចំនួន១១២ហិកតា)

ប្រព័ន្ធកូអរដោនេ :

តំបន់ទី : 48N

ចំណោលផែនទី : UTM

ទិន្នន័យយោង : WGS1984

ប្រភពទិន្នន័យ:

ព្រំប្រទល់: នាយកដ្ឋានភូមិសាស្ត្រ

គំរបព្រៃ: រដ្ឋបាលព្រៃឈើ ឆ្នាំ ២០០២



ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ១៨៣ អនក្រ.បក

អនុក្រឹត្យ

ស្តីពី

ការកាត់ដីទំហំសរុប ១៨៩៩ ហិកតា ចេញពីដីព្រៃសម្បទាន ក្រុមហ៊ុន សាម លីញ ក្នុងផ្ទៃដីទំហំ ១៤៥៩ ហិកតា និងដីគម្របព្រៃដែលមានដីកាដកហូត លេខ០១៧/០៦ អគខ.ជព ក្នុងផ្ទៃដីទំហំ ៤៤០ ហិកតា និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ ដើម្បីធ្វើប្រទានកម្មជាកម្មសិទ្ធិ ជូនប្រជាពលរដ្ឋ ចំនួន ៤៧៨ គ្រួសារ ដែលបាន កាន់កាប់ ប្រើប្រាស់ និងដាំដុះជាក់ស្តែង នៅភូមិត្រពាំងឫស្សី ឃុំតំបែរ ស្រុកតំបែរ ខេត្តកំពង់ចាម

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២នសចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឲ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០២/០១៦ ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០២ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីព្រៃឈើ

- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨០៦/៣៣៩ ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០០៦ ស្ដីពីគោលការណ៍ និងបញ្ញត្តិអន្តរកាលនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ
- បានឃើញអនុក្រឹត្យលេខ៦២ អនក្រ.បក ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៩ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញអនុក្រឹត្យលេខ១៧ អនក្រ.បក ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០០ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ៨៨អនក្រ.បកចុះថ្ងៃទី០១ខែធ្នូ ឆ្នាំ២០០០ស្ដីពីការបង្កើតក្រុមប្រឹក្សាគោលនយោបាយដីធ្លី
- បានឃើញអនុក្រឹត្យលេខ១១៨ អនក្រ.បក ចុះថ្ងៃទី០៧ ខែតុលា ឆ្នាំ២០០៥ ស្ដីពីការគ្រប់គ្រងដីរដ្ឋ
- បានឃើញអនុក្រឹត្យលេខ១៤៦ អនក្រ.បកចុះថ្ងៃទី២៧ខែធ្នូ ឆ្នាំ២០០៥ ស្ដីពីសម្បទានដីសេដ្ឋកិច្ច
- បានឃើញសារាចរលេខ០២ សរ ចុះថ្ងៃទី០៩ ខែកុម្ភៈ ឆ្នាំ១៩៩៥ ស្ដីពីការប្រឡូកប្រណាំងកែលំអសោភ័ណភាពខេត្តក្រុងទាំងប្រទេស
- បានឃើញសារាចរលេខ ០៥ សរ ចុះថ្ងៃទី ២៦ ខែ ឧសភា ឆ្នាំ ២០០០ របស់រាជរដ្ឋាភិបាលស្ដីពីសន្តិសុខស្បៀង និងអាហារូបត្ថម្ភនៅក្នុងព្រះរាជាណាចក្រកម្ពុជា
- បានឃើញសារាចរលេខ ០២ សរ ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០០៧ ស្ដីពីការកាន់កាប់ដីរដ្ឋដោយខុសច្បាប់
- លិខិតលេខ ២០៨០ លខ.ក.ច ចុះថ្ងៃទី ០២ ខែ តុលា ឆ្នាំ ២០១២ របស់គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តកំពង់ចាម
- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

សម្រេច

មាត្រា ១.

ត្រូវបានកាត់ដីទំហំសរុប ១៨៩៩ ហិកតា ចេញពីដីព្រៃសម្បទាន ក្រុមហ៊ុន សាម លីញ នូវផ្ទៃដីទំហំ ១៤៥៩ ហិកតា និងដីគម្របព្រៃ ដែលមានដីកាដកហូត លេខ០១៧/០៦ អគ.៨ព នូវផ្ទៃដីទំហំ ៤៤០ ហិកតា និងធ្វើអនុបយោគជាដី ឯកជនរបស់រដ្ឋ នៅភូមិត្រពាំងឫស្សី ឃុំតំបែរ ស្រុកតំបែរ ខេត្តកំពង់ចាម តាមប្រព័ន្ធកូអរដោណេ Project UTM Zone 48N Datum WGS1984 និងមាននិយាមកាដូចកំណត់ក្នុងផែនទីឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ។

មាត្រា ២..

ត្រូវបានប្រគល់អាណត្តិកាន់កាប់ និងបែងចែកដីឯកជនរបស់រដ្ឋដូចមានចែងក្នុងមាត្រា១ ជូនគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តកំពង់ចាម ដើម្បីធ្វើការគ្រប់គ្រង និងប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋចំនួន ៨៧៨ គ្រួសារ ដែលបានកាន់កាប់ ប្រើប្រាស់ និងដាំដុះជាក់ស្តែង នៅភូមិត្រពាំងឫស្សី ឃុំតំបែរ ស្រុកតំបែរ ខេត្តកំពង់ចាម ។

មាត្រា ៣ ..

ក្នុងពេលដំណើរការវាស់វែងនិងបែងចែកជាក់ស្តែង គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តកំពង់ចាម ត្រូវកាត់ចេញនូវចំណែកដីមួយចំនួនសមស្រប ដើម្បីរក្សាទុកសម្រាប់បម្រើផលប្រយោជន៍សាធារណៈ ទាំងសម្រាប់ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្តនិងសង្គមនៅក្នុងមូលដ្ឋាន។

មាត្រា ៤ ..

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយពីអនុក្រឹត្យនេះត្រូវចាត់ទុកជានិរាករណ៍ ។

មាត្រា ៥..

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងអភិបាលនៃគណៈអភិបាលខេត្តកំពង់ចាម ត្រូវអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែ ១០ ឆ្នាំ ២០១២

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល៖

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា*
- *អគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិដោះស្រាយវិវាទដីធ្លី*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ៥*
- *រាជកិច្ច*
- *ឯកសារកាលប្បវត្តិ*

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ:១៥៤ . អនក្រ.បក

អនុក្រឹត្យ
ស្តីពី
ការកាត់ដីចេញពីសម្បទានដីសេដ្ឋកិច្ចរបស់ក្រុមហ៊ុន តាពីម៉ិច ទូទាំងផ្ទៃដីធំហំ ១០២០ ហិកតា និងធ្វើអនុបយោគ ជាដីឯកជនរបស់រដ្ឋ ដើម្បីធ្វើប្រទានកម្មជាកម្មសិទ្ធិ ជូនប្រជាពលរដ្ឋ ចំនួន ៧២៩ គ្រួសារ ដែលបានកាន់កាប់ ប្រើប្រាស់ និងដាំដុះជាក់ស្តែង និងរក្សាទុកជាដីព្រៃបម្រុងសម្រាប់សហគមន៍ព្រៃឈើ នៅឃុំក្រាំងលាវ ស្រុករលាប្អៀរ ខេត្តកំពង់ឆ្នាំង

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២នសចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឲ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០២/០១៦ ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០២ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីព្រៃឈើ
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៨០៦/៣៣៩ ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០០៦ ស្តីពីគោលការណ៍ និងបញ្ញត្តិអន្តរកាលនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋនិងរបស់នីតិបុគ្គលសាធារណៈ
- បានឃើញអនុក្រឹត្យលេខ៦២ អនក្រ.បក ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

- បានឃើញអនុក្រឹត្យលេខ១៧ អនក្រ.បក ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ៨៨ អនក្រ.បក ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០០០ ស្តីពីការបង្កើតក្រុមប្រឹក្សាគោលនយោបាយដីធ្លី
- បានឃើញអនុក្រឹត្យលេខ១១៨ អនក្រ.បក ចុះថ្ងៃទី០៧ ខែតុលា ឆ្នាំ២០០៥ ស្តីពីការគ្រប់គ្រងដីរដ្ឋ
- បានឃើញអនុក្រឹត្យលេខ១៤៦ អនក្រ.បកចុះថ្ងៃទី២៧ខែធ្នូ ឆ្នាំ២០០៥ ស្តីពីសម្បទានដីសេដ្ឋកិច្ច
- បានឃើញសារាចរលេខ ០២ សរ ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០០៧ ស្តីពីការកាន់កាប់ដីរដ្ឋដោយខុសច្បាប់
- តាមសំណើលេខ ៦៣៥លស ចុះថ្ងៃទី២ ខែតុលា ឆ្នាំ២០១២ របស់គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តកំពង់ឆ្នាំង
- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

សម្រេច

មាត្រា ១.-

ត្រូវបានកាត់ដីចេញពីសម្បទានដីសេដ្ឋកិច្ចរបស់ ក្រុមហ៊ុន ភាពីម៉ិច នូវផ្ទៃដីទំហំ ១០២០ ហិកតា និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ នៅឃុំក្រាំងលាវ ស្រុករលាប្អៀរ ខេត្តកំពង់ឆ្នាំង ដែលស្ថិតនៅក្នុងភូមិដូចខាងក្រោម៖

- ផ្ទៃដីទំហំ ៩០៨ ហិកតា នៅភូមិអណ្តូងប្រេង តាមប្រព័ន្ធកូអរដោណេ Project UTM Zone 48N Datum wgs 1984 និងមាននិយាមកាដូចកំណត់ក្នុងផែនទីឧបសម្ព័ន្ធ (1) នៃអនុក្រឹត្យនេះ
- ផ្ទៃដីទំហំ ៥២៧ ហិកតា នៅភូមិជ្រលងកក់ តាមប្រព័ន្ធកូអរដោណេ Project UTM Zone 48N Datum wgs 1984 និងមាននិយាមកាដូចកំណត់ក្នុងផែនទីឧបសម្ព័ន្ធ (2) នៃអនុក្រឹត្យនេះ
- ផ្ទៃដីទំហំ ៨៥ ហិកតា ត្រូវរក្សាទុកជាដីព្រៃបម្រុងសម្រាប់សហគមន៍ព្រៃឈើ។

មាត្រា ២.-

ត្រូវបានប្រគល់អាណត្តិកាន់កាប់ និងបែងចែកដីរបស់រដ្ឋដូចមានចែងក្នុងមាត្រា១ ជូនគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តកំពង់ឆ្នាំង ធ្វើការគ្រប់គ្រង និងប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋចំនួន ៣១១ គ្រួសារ នៅភូមិអណ្តូងប្រេង និង៩១៨ គ្រួសារ នៅភូមិជ្រលងកក់ ឃុំក្រាំងលាវ ស្រុករលាប្អៀរ ខេត្តកំពង់ឆ្នាំង ដែលបាន កាន់កាប់ ប្រើប្រាស់ និងដាំដុះជាក់ស្តែង និងរក្សាទុកជាដីព្រៃបម្រុងសម្រាប់សហគមន៍ព្រៃឈើ ។

មាត្រា ៣ .-

ក្នុងពេលដំណើរការវាស់វែង និងបែងចែកជាក់ស្តែង គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តកំពង់ឆ្នាំង ត្រូវកាត់ចេញនូវចំណែកដីមួយចំនួនសមស្របដើម្បីរក្សាទុកសម្រាប់បម្រើផលប្រយោជន៍សាធារណៈ ទាំងសម្រាប់ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងសង្គម នៅក្នុងមូលដ្ឋាន។

មាត្រា ៤..

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយពីអនុក្រឹត្យនេះត្រូវចាត់ទុកជានិរាករណ៍ ។

មាត្រា ៥..

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងអភិបាលនៃគណៈអភិបាលខេត្តកំពង់ឆ្នាំង ត្រូវអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែ ៧ ឆ្នាំ២០១២

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល៖

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការ រាជរដ្ឋាភិបាល*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា*
- *អគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិដោះស្រាយវិវាទដីធ្លី*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ៥*
- *រាជកិច្ច*
- *ឯកសារកាលប្បវត្តិ*

ឧបសម្ព័ន្ធអនុក្រឹត្យលេខ ១៧៨អនក្រ.បក ចុះថ្ងៃទី.២៩... ខែ .តុលា..... ឆ្នាំ២០១២ ស្តីពីការកាត់ចេញពីគម្របព្រៃឈើឆ្នាំ២០០២ ពីដីសម្បទានសេដ្ឋកិច្ចក្រុមហ៊ុនគាំពីម៉ិច និងធ្វើអនុបយោគមកជាដីឯកជនរបស់រដ្ឋនូវផ្ទៃដីទំហំ ១០២០ ហិកតា នៅឃុំក្រាំងលាវ ស្រុករលាប្អៀរ ខេត្តកំពង់ឆ្នាំង និងធ្វើប្រទានកម្មជូនប្រជាពលរដ្ឋចំនួន ៧២៩ គ្រួសារដែលបានកាន់កាប់ ប្រើប្រាស់និងដាំដុះជាក់ស្តែង



ចំណុច	X	Y
1	446350	1346972
2	447128	1347172
3	447628	1347425
4	447868	1347315
5	449464	1348874
6	450306	1348725
7	451446	1347825
8	451595	1346450
9	450770	1346272
10	449616	1346462
11	449974	1345854
12	449314	1345404
13	449090	1344913

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខៈ ១៨៥ អនក្រ.បក

អនុក្រឹត្យ
ស្តីពី
ការកាត់ចេញពីដីតំបន់ដែនជំរកសត្វព្រៃរនាមដូនសំ ទូទផ្ទៃដីទំហំ ២ ៨២៨ ហិកតា និងធ្វើអនុបយោគ ជាដីឯកជនរបស់រដ្ឋ ដើម្បីធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ចំនួន ៤៤១ គ្រួសារ ដែលបានកាន់កាប់ ប្រើប្រាស់ និងដាំដុះជាក់ស្តែង នៅភូមិគ្រួសក្រហម ឃុំអូររំដួល ស្រុកភ្នំព្រឹក ខេត្តបាត់ដំបង

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
